00815547



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 06 / 2012
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២៨ ខែ ឧសភា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៦៤

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, លោក វ៉េង ហ៊ត់, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN , លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ទី ស្រីនណា លោក គឹម ម៉េងឃី, លោកស្រីមេធាវី Laure DESFORGES, លោក Barnabé NEKUIE |
| សាក្សី៖ លោក នី កន TCW-487 |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.00 |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.00 |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង ១៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់ | ជនជាប់ចោទ អៀង សារី<br>ជនជាប់ចោទ នួន ជា | ៩.១០<br>១២.០៥ | 0៩.១០<br>១២.០៥ |
| សេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងនឹងឯកសារ D366/7.1.188 | អង្គជំនុំជម្រះ | ៩.១០ | ៩.១៥ |
| ការសួរសំណួរដល់សាក្សី នី កន TCW-487 | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ៩.១៥ | ១៦.00 |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**ការស្នើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី (សម្រាប់រយៈពេលពេញមួយថ្ងៃ) និងជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងសាលសវនាការ ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំ។

**សេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងនឹងឯកសារ** D366/7.1.188

អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងនឹងឯកសារ D366/7.1.188(សូមមើលសេចក្តីសម្រេចខាងក្រោម)។

**ការសួរសំណួរដល់សាក្សី នី កន** TCW-487

អង្គជំនុំជម្រះ និងសហព្រះរាជអាជ្ញាតាំងសំណួរដល់សាក្សី នី កន ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1607 | D366/7.1.188 | 00442359-00442374 00574533-00574545 00574546-00574557 | លក្ខន្តិកៈ សម្ព័ន្ធយុវជន កុម្មុយនីសកម្ពុជា "ស. យុវកក" Statute of CPK Youth league Statute of CPK Youth league | P | | | |
| E3/9 | D222/1.15 | 00755579-00755583 00396177-00396757 00639445-00640068 | [លិខិតបញ្ជាក់ការជំនួសឯកសារ] [Partial T.] សៀវភៅនិពន្ធដោយ Philip Short មានចំណងជើងថា៖ "ប៉ុល ពត ប្រវត្តិនៃសុបន្តិអាក្រក់មួយ" [Surrogate Sheet] Book by Philip Short entitled "Pol Pot, The History of a Nightmare" [Feuille remplacée] Livre écrit par Philip Short intituté "Pol Pot, Anatomie d'un cauchemar" | P | | 00396185, 00396347, 00396699, 00396393, 00396452, 00396476 | 00639630, 00639706, 00639780, 00639800 |
| E3/130 | D366/7.1.187 | 00442251-00442281 00184022-00184047 00292914-00292934 | [លិខិតបញ្ជាក់ការជំនួសឯកសារ] លក្ខន្តិកៈ បក្សកុម្មុយនិស្តកម្ពុជា [Surrogate Sheet] The CPK statute [Feuille remplacée] Status du Parti Communiste du Kampuchea | P | 00442253-54, 00442255, 00442257, 00442261 | 00184024, 00184025, 00184027, 00184032 | 00292916, 00292917, 00292919, 00292922 |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
|---|
| • អង្គជំនុំជម្រះសម្រេចលើឯកសារ D366/7.1.188 ដែលបានស្នើដោយសហព្រះរាជអាជ្ញា៖<br>"ក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានស្នើសុំឲ្យតំណាងសហព្រះរាជអាជ្ញាធ្វើការបញ្ជាក់ទៅលើឯកសារ D366/7.1.188 ដែលមាន ចំណងជើងថា "លក្ខន្តិកៈសម្ព័ន្ធយុវជនកុម្មុយនីសកម្ពុជា" ព្រោះសហព្រះរាជអាជ្ញាមានបំណង យោងទៅលើឯកសារនេះ នៅពេលតាំងសំណួរដល់សាក្សី TCW-487 ។ តាមការពិនិត្យមើលសំណុំ រឿងដំបូងវាបង្ហាញថា ឯកសារនេះមិនមាននៅក្នុងបញ្ជីឯកសារដំបូង ដែលសហព្រះរាជអាជ្ញា បានដាក់ជូនអង្គជំនុំជម្រះក្នុងខែ មេសា ឆ្នាំ ២០១១ (ឯកសារ E9/31) និងនៅខែ កក្កដា ឆ្នាំ ២០១១ (ឯកសារ E109/4) នោះទេ ។ បន្ថែមលើការបញ្ជាក់របស់តំណាងសហព្រះរាជអាជ្ញា ដែលបានធ្វើក្នុង អំឡុងពេលសវនាការកាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ នោះ ឥឡូវនេះ អង្គជំនុំ ជម្រះសូមបញ្ជាក់ថា ឯកសារនេះមាននៅក្នុងបញ្ជីឯកសារដំបូងទាំងពីររបស់សហព្រះរាជអាជ្ញា ។ ដោយឯកសារនេះមាននៅក្នុងឧបសម្ព័ន្ធទី២ នៃឯកសារ E109/4 ដូច្នេះ ឯកសារ នេះក៏ចាត់ទុកថា ត្រូវបានវាយតម្លៃដោយអង្គជំនុំជម្រះផងដែរចំពោះភាពអាចទទួលយកបាននៃឯកសារ ដែលបានស្នើសុំ ដោយសហព្រះរាជអាជ្ញា (ដូចមានបញ្ជាក់ក្នុងសេចក្តីសម្រេចឯកសារ E185) ។ ផ្អែកតាមគោល ការណ៍ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចឯកសារ E185 អង្គជំនុំជម្រះបានពិនិត្យឡើងវិញនូវ ឯកសារ D366/7.1.188 នេះ ដូច្នេះ អង្គជំនុំជម្រះចាត់ទុកថា ឯកសារនេះត្រូវបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះ ។ ហេតុដូច្នេះ ឯកសារនេះនឹងត្រូវចាត់ថ្នាក់ទៅជាប្រភេទឯកសារ E3 នៅពេលឆាប់ៗ ខាងមុខតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ន ឯកសារនេះនឹងរក្សានូវលេខឯកសារ D366/7.1.188 ដដែល ។"<br><br>• អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា (១២.០៥) ចូលរួមដំណើរការសវនាការពីបន្ទប់ ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។<br><br>• បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង វិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញ (ដោយឡែកជនជាប់ចោទ អៀង សារី ត្រូវនាំមកបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) ឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៩ ខែ |

ឧសភា ឆ្នាំ ២០១២ ។

- បង្គាប់ឲ្យនាំសាក្សី TCW-487 ត្រឡប់ទៅផ្ទះវិញ និងបង្គាប់ឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ ។

| **កាលបរិច្ឆេទបន្តសវនាការ៖** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ២៩ ខែ ឧសភា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Matteo CRIPPA